
ប្រលោមលោក ដោយ សុខ ចាន់ផល
វគ្គ បញ្ចប់
សមាគមសេរីភាព
LIBERTY ASSOCIATION

# Winter Love

និពន្ធដោយ សុខ ចាន់ផល

# ឆ្នាំ ២០០៨

មួយឆ្នាំកន្លងផុតទៀតហើយ។ ខែវងានេះ ខ្ញុំបានយករូបថតរបស់ខ្ញុំ ទៅដាក់តាំងក្នុងពិធីពិព័រណ៍រូបថតមួយ ឈ្មោះថា "ទេសភាពស្រុកខ្មែរ" ដែលគេដាក់តាំងរូបថតទេសភាពគ្រប់រដូវកាល។ មានរូបថតជាច្រើនដែលថតដោយអ្នកថតរូបខ្មែរ និងបរទេស។ របស់ខ្ញុំគឺរូបទេសភាពខែវងា មានដូចជាខ្លែងប្រឹងហោះតាមខ្យល់ តែត្រូវគេចងជាប់ខ្សែគ្មានសេរីភាព... រូបវាលស្រែពណ៌មាស ដែលដើមស្រូវទាំងឡាយត្រូវខ្យល់បក់បោក ឲ្យបាក់កដួលរាបគួរឲ្យអាណិត... រូបដើមគមួយដើម ខំត្រដរដុះស្មៀមផ្ទឹងក្បែរមាត់ប្រឡាយ រស់នៅកំព្រាឯកា... គឺសុទ្ធសឹងតែជាទេសភាពកម្សត់ៗ។

អារម្មណ៍ខ្ញុំក្នុងពេលនេះ មើលឃើញពិភពលោកសែនក្រៀមក្រំណាស់។ បេះដូងស្វិតស្រពោនបណ្តាលឲ្យខ្ញុំថតរូបភាពកម្សត់ៗ ឯដួងចិត្តស្ដោកស្ដាញមជំរុញឲ្យខ្ញុំកាត់អត្ថន័យរូបភាពដោយសម្ដីអពមង្គល។ វេលានេះខ្ញុំគួរតែរីករាយ គួរតែមានមោទកភាពចំពោះខ្លួនឯង ប៉ុន្តែខ្ញុំបែរជាយល់ថា ជីវិតខ្ញុំសែនឯកា គ្មានអ្នកណារំលែកក្ដីសប្បាយរីករាយនេះជាមួយខ្ញុំឡើយ។ មនុស្សឯកាម្នាក់ដែលកំពុងតែសើចសប្បាយម្នាក់ឯងវាមិនមែនជារឿងសប្បាយទេ តែគឺជារឿងដ៏កម្សត់បំផុត។

មែន! មានមនុស្សជាច្រើនចូលមកមើលរូបថតរបស់ខ្ញុំ សូម្បីតែលោកប៉ាអ្នកម៉ាក់ខ្ញុំក៏អញ្ជើញមក កញ្ញា ប្អូនធម៌ខ្ញុំក៏មក... តើហេតុអ្វីក៏ខ្ញុំមិនអាចចែករំលែកក្ដីរីករាយនេះជាមួយពួកគេទៅ?

-វ៉ាក់អើ៎! កំពុងតែគិតស្អីហ្នឹង?

កញ្ញា ប្រហែលជាយល់ថា ខ្ញុំកំពុងតែភ្លឹកស្មារតីមិនដឹងថានាងដើរមករកខ្ញុំហើយ បានជាខំពញ្ញាក់ខ្ញុំយ៉ាងនេះ។ តាមពិតខ្ញុំឃើញនាងដើរមករកខ្ញុំច្បាស់ចែស គ្រាន់តែខ្ញុំមិនបានចាប់

អារម្មណ៍មើលទៅនាង។ អេ... ទើបតែមើលឃើញច្បាស់មែនតើ ថា កញ្ញា ថ្ងៃនេះតុបតែងខ្លួនស្អាតខុសពីធម្មតា ដូចចង់មកបង្អួតឲ្យខ្ញុំលង់ស្នេហ៍លើនាងអ៊ីចឹង។ គេថាមនុស្សស្រីមានល្អគន់និងល្អឆើត ឯ កញ្ញា នេះ គឺចូលជំពូកមនុស្សស្រីល្អគន់ហើយ ព្រោះជួបគ្នាដំបូងខ្ញុំមើលមិនដឹងថា នាងស្អាតត្រង់ណាទេ តែលុះមើលមួយឆ្នាំ ពីរឆ្នាំ ថ្ងៃនេះទើបដឹងច្បាស់ថា នាងពិតជាស្រីស្អាតម្នាក់មែន។

-បងកំពុងគិតស្អីហ្នឹង? ច្រណែនប៉ាម៉ាក់ស្រលាញ់គ្នាទេដឹង?

សួរម្តងមិនឆ្លើយ ក៏សួរម្តងទៀត។ ភ្នែកនាងសម្លឹងមុខខ្ញុំគ្មានប្រិច។ នៅជិតនាងម្តងៗ ខ្ញុំដូចជាចង់តែរត់ចេញ ព្រោះតឡូវនាងចេះតែព្យាយាមធ្វើខ្លួនស្និទ្ធស្នាលនឹងខ្ញុំ រហូតធ្វើឱ្យខ្ញុំសង្ស័យថា នាងកំពុងតែតាមស្រលាញ់ខ្ញុំហើយ។ ខ្ញុំញញឹមស្ងើរ ឆ្លើយទៅនាងវិញ៖

-ម៉េចក៏កញ្ញាដឹងចិត្តខ្ញុំម្ល៉េះ?

-រាល់ថ្ងៃខ្ញុំចាប់អារម្មណ៍បងប៉ុណ្ណា បងមិនដឹងទេឬអ្វី? មើលចុះ! បងធ្វើមុខដូចមាននរណាស្លាប់អ៊ីចឹង។ តើបងកើតទុក្ខរឿងអី? រឿងស្នេហាអ្ហ? បងឯងនេះដូចខ្ញុំថាតាំងពីឆ្នាំមុនមិនខុស គឺមិនដែលពេញចិត្តនឹងអ្វី ដែលខ្លួនឯងកំពុងតែមានទេ... ខ្ញុំនេះយកចិត្តទុកដាក់លើបងជាងគេបំផុតហើយ ដឹងទេ? មើលនែ៎ក ខ្ញុំដឹងថាបងចូលចិត្តអានរឿងកំប្លែង ក៏ទៅទិញសៀវភៅរឿងកំប្លែងមកឲ្យបង។ ណេ៎ះ យកទៅអានទៅ ក្រែងមុខរីករិញ!

ខ្ញុំទទួលសៀវភៅរឿងកំប្លែងនោះពីដៃនាង៖

-អរគុណច្រើន!

-បងដឹងទេ? ពេលខ្ញុំទៅទិញសៀវភៅរឿងកំប្លែងនេះ ខ្ញុំបានជួបរឿងកំប្លែងពិតប្រាកដមួយ គួរឲ្យចង់សើចមែនទែន។ កាលណោះខ្ញុំទិញរឿងកំប្លែងបានហើយ ក៏មករកមើលរឿងប្រលោមលោក ស្រាប់តែប្រទះក្មេងប្រុសម្នាក់អាយុប្រហែលជា ១៤-១៥ ឆ្នាំ កំពុងតែកាន់រឿងប្រលោមលោកមួយក្បាល ដែលមានសរសេរអក្សរលើក្របថា "ហាមអាយុក្រោម១៨ឆ្នាំអាន"។ ខ្ញុំក៏

សួរវាថា «អេ! អូនឯងអាយុមិនទាន់គ្រប់១៨ឆ្នាំផង ម៉េចក៏ទិញសៀវភៅនេះ?» បងដឹងថាវាឆ្លើយយ៉ាងម៉េចទេ? ...វាឆ្លើយថា «ខ្ញុំទិញយកទៅទុកមិនបានអេ្ហះ? ទុកដល់អាយុ១៨ឆ្នាំ ចាំអានទៅ!»

ព្រោះខ្ញុំនៅស្ងៀម អត់ព្រមសើច នាងក៏សួរ៖

-ម៉េច? បងរកកន្លែងសើចមិនឃើញអ្ហ?

ខ្ញុំក៏សើចទាំងបង្ខំចិត្តដាក់នាង។ តាមពិតខ្ញុំសើចមិនចេញទេ ហើយថែមទាំងចង់ស្រែកយំឲ្យឮទៀតផង ព្រោះអ្នកដែលយកចិត្តទុកដាក់ ចង់ឲ្យខ្ញុំសើចសប្បាយ មិនមែនជាមនុស្សដែលខ្ញុំស្រលាញ់។ ដឹងទេ? ថាពេលនេះខ្ញុំនឹកមនុស្សម្នាក់ស្ទើរតែឆ្កួតទៅហើយ។

គ្រានោះ កញ្ញា ប្តូរពីសំឡេងខ្លាំងៗ ក្លាយជាសំឡេងដ៏ស្ងប់បន្លឺមករកខ្ញុំថា៖

-មើលទៅបង គ្មានរឿងអ្វីឲ្យសប្បាយចិត្តកើតទេ។ ស្ថានភាពបងយ៉ាងនេះ គួរតែព្រមមករស់នៅជាមួយលោកប៉ាអ្នកម៉ាក់វិញ

ទៅ។ កុំរស់នៅម្នាក់ឯងទៀត។ ខ្ញុំមិនចង់ដឹងថា បងកើតទុក្ខព្រោះរឿងស្អីទេ តែខ្ញុំចង់ឲ្យបងដឹងថា ខ្ញុំនឹងព្យាយាមធ្វើឲ្យបងបានសប្បាយចិត្តវិញ... ទោះដោយវិធីណាក៏ដោយ... បងដឹងទេ? ពេលឃើញបងធ្វើឫកពាបែបនេះ ខ្ញុំឈឺចាប់ប៉ុណ្ណា? ...ទោះជាបងមិនខ្វល់នឹងខ្ញុំ ក៏បងគួរតែគិតពីលោកប៉ាអ្នកម៉ាក់របស់បងផង។

ខ្ញុំមិនឆ្លើយតបនឹងនាងទេ គ្រាន់តែសម្លឹងតាមសម្ដីរបស់នាងមើលទៅលោកប៉ាអ្នកម៉ាក់។ ឥឡូវនេះទំនាក់ទំនងរបស់ពួកយើងល្អប្រសើរណាស់។ ខ្ញុំមិនដែលឈ្លោះប្រកែកជាមួយលោកប៉ាទៀតទេ ព្រោះគំនុំគុំកួនទាំងអំបាលម៉ានរវាងខ្ញុំនិងគាត់ ត្រូវបានរលាយទៅតាមគ្រោះថ្នាក់មិនស្លាប់ ដែលខ្ញុំជួបកាលពីឆ្នាំមុននោះបាត់អស់ទៅហើយ។

ពិតណាស់... ជីវិតមនុស្សមិនមែនរស់នៅសម្រាប់តែរឿងស្នេហាមួយមុខឯណា? ម៉េចក៏ខ្ញុំមិនជ្រើសរើសសុភមង្គលផ្សេងៗនៅជុំវិញខ្លួននេះផងទៅ? គំនិតចេះតែគិត ដួងចិត្តរឹតតែ

ស្មុគស្មាញ។ នឹកមិនដល់ ពេលខ្ញុំងាកមុខមករក កញ្ញា វិញ ក៏ឃើញនាងសម្រក់ទឹកភ្នែកដាក់ខ្ញុំ៖

-ខ្ញុំដឹងថា បងចាត់ទុករូបខ្ញុំត្រឹមតែជាប្អូនស្រីប៉ុណ្ណោះ... តែខ្ញុំ... ត្រូវតែប្រាប់បងថា... ខ្ញុំស្រលាញ់បង...

ពោលពាក្យនេះចប់ កញ្ញារត់ចេញពីមុខខ្ញុំបាត់ ទុកឲ្យខ្ញុំនៅឈរទ្រឹង ដោយចិត្តនឹកអាណិតនាងផង ច្របូកច្របល់នឹងអារម្មណ៍ខ្លួនឯងផង។ រឿងរ៉ាវនៅលើលោកនេះសុទ្ធតែពិបាកដោះស្រាយយ៉ាងនេះឬ? មនុស្សម្នាក់ៗរងទុក្ខដោយសារតែមនោសញ្ចេតនាខ្លួនឯង។ កញ្ញាស្រលាញ់ខ្ញុំ តែខ្ញុំស្រលាញ់ប្រភា ឯប្រភា មិនស្រលាញ់ខ្ញុំ... ហេតុអ្វីក៏ព្រហ្មលិខិតមិនព្រមចារឲ្យមនុស្សគ្រប់គ្នា ស្រលាញ់តែអ្នកណាដែលស្រលាញ់ខ្លួនទៅ? កញ្ញាមិនមែនអន់ឯណា? ហេតុអ្វីនាងត្រូវមកខូចចិត្តព្រោះតែស្រលាញ់ខ្ញុំ? ប្រភាមានល្អលើសកញ្ញា មួយមេឃមួយដីឯណា ម៉េចក៏ខ្ញុំមិនអាចបំភ្លេចនាង មកស្រលាញ់កញ្ញាជំនួសវិញ? ប៉ុន្តែស្នេហាគឺចិត្តជាអ្នកបញ្ជា មិនមែនបញ្ញាជាអ្នក

បញ្ហាទេ។ នៅក្នុងភពផែនដីនេះមិនខ្វះទេស្រីល្អ ប៉ុន្តែមនុស្សស្រីដែលខ្ញុំស្រលាញ់គឺមានតែម្នាក់ប៉ុណ្ណោះ។

ទំព័រជីវិតរបស់ខ្ញុំនាថ្ងៃនេះ គឺហាក់កំពុងឈានទៅរកជំងឺធ្លាក់ទឹកចិត្តហើយ ព្រោះកម្លាំងចិត្តក្នុងការរស់នៅរបស់ខ្ញុំដូចជារលាយសូន្យគួរឲ្យខ្លាច។ ហេតុនេះនាពេលរសៀល ខ្ញុំក៏បានទៅផ្ទះរបស់មិត្តភក្តិម្នាក់ ដើម្បីមានគ្នាប្រឹក្សា។ គាត់ឈ្មោះ ស្នាដៃ មានអាយុច្រើនជាងខ្ញុំ គឺជាមនុស្សដែលខ្ញុំតែងតែគោរព។ ខ្ញុំបានសាស័ព្ទរឿងរ៉ាវក្នុងចិត្តប្រាប់គាត់ រួចគាត់ក៏ពោលថា៖

-បើស្រលាញ់មនុស្សម្នាក់ពិតប្រាកដ ហេតុអ្វីក៏ចាំបាច់ខ្វល់ថា គេស្រលាញ់យើងវិញ ឬក៏អត់?

ខ្ញុំតបទៅគាត់វិញ៖

-ស្រលាញ់គឺគ្រាន់តែចង់ឱ្យគេបានសុខ ប៉ុន្តែខ្ញុំនៅតែឈឺចាប់គ្រប់ពេលឮសំឡេងរបស់នាង។ រាល់យប់ខ្ញុំតែងបើកវិទ្យុស្តាប់សំឡេងនាង... ខ្ញុំចង់ជួបនាងណាស់... ហើយថ្ងៃនេះខ្ញុំចង់ឱ្យ

នាងទៅចូលពិធីពិព័រណ៍រូបថតរបស់ខ្ញុំ... ស្នេហាគឺជាការលះបង់ មែនទេ? ប៉ុន្តែនៅពេលស្រមៃឃើញនាងស្និទ្ធស្នាលជាមួយអ្នកដទៃ បេះដូងខ្ញុំក៏ស្រែកប្រាប់ខ្ញុំថា វាចុកចាប់ណាស់ វាទទួលមិនបានទេ...

-តើនេះឬគឺជាស្នេហារបស់ប្អូននោះ? ចិត្តមនុស្សបរិសុទ្ធណាស់ ហេតុអ្វីក៏ក្តីស្រលាញ់របស់មនុស្សមិនបរិសុទ្ធផងទៅ?

ឮគាត់ថាយ៉ាងនេះ ខ្ញុំក៏នឹកឃើញរឿងមួយ៖

-កាលស្គាល់គ្នាដំបូង ប្រភាធ្លាប់សួរខ្ញុំតាមសំបុត្រថា ហេតុអ្វីក៏ខ្ញុំចង់រាប់អាននាងម្ល៉េះ? បើគ្មានប្រយោជន៍ក៏មនុស្សមិនតស៊ូធ្វើអ្វីដែរ មែនទេ?

-នាងសួរនោះគឺត្រូវហើយ។ ប្អូនត្រូវទទួលស្គាល់ថា ប្អូនស្រលាញ់នាង គឺប្អូនចង់បានប្រយោជន៍ពីនាង។ នេះមិនមែនជាក្តីស្រលាញ់ដ៏បរិសុទ្ធទេ ទើបប្អូននៅតែមិនអាចទទួលក្តីស្រលាញ់ពីនាងវិញបាន។ មនុស្សពីរនាក់ធ្វើបុណ្យដូចគ្នា ហេតុអ្វីក៏បានបុណ្យខុសគ្នា? នោះគឺព្រោះមនុស្សម្នាក់ធ្វើបុណ្យ

ដោយចិត្តជ្រះថ្លា តែមនុស្សម្នាក់ទៀតធ្វើបុណ្យដោយតណ្ហា។ គេមិនយល់សោះ ថាការធ្វើបុណ្យដោយប្រាថ្នាចង់បានបុណ្យតបស្នង វាបែរជាមិនអាចទទួលបានបុណ្យទៅវិញ។ នេះហើយគឺជាដំណើរធម្មជាតិដ៏បរិសុទ្ធ។

បងស្នាដៃ ឈប់និយាយ ដោយចង់ឲ្យខ្ញុំបញ្ចេញយោបល់ តែខ្ញុំរកនឹកនិយាយស្ទើមិនចេញសោះ។ ទស្សនៈរបស់គាត់កំពុងតែបំផុសសំណួរឲ្យខ្ញុំឆ្លើយថា តើស្នេហារបស់ខ្ញុំលើរូបប្រភា គឺគ្រាន់តែជាការប្រាថ្នាទេ មែនទេ? បងស្នាដៃ ពោលបន្ត៖

-ក្តីស្រលាញ់គឺជារឿងល្អណាស់ មិនមែនជារឿងប្រច័ណ្ឌប្រណែនទាល់តែសោះ។ ប្អូនមិនគួរខ្វល់ថា មនុស្សដែលប្អូនស្រលាញ់ គេស្រលាញ់អ្នកណាខ្លាំងជាងប្អូនឡើយ។ ហេតុអ្វីក៏ប្អូនចង់យកនាង មកធ្វើជាកម្មសិទ្ធិរបស់ខ្លួន? តើនៅលើលោកនេះមានអ្វីជារបស់យើងទៅ បើសូម្បីតែខ្លួនយើងក៏មិនមែនជារបស់យើងផង? ចុះទម្រាំមនុស្សដែលយើងស្រលាញ់ តើអាចជាកម្មសិទ្ធិរបស់យើងទៅរួចទេ?

សម្តីគាត់សុទ្ធតែត្រឹមត្រូវទាំងអស់ ប៉ុន្តែវាដូចជាគ្មានឥទ្ធិពលធ្វើឲ្យជីវិតមនុស្សមានសង្ឃឹមសោះ។ ខ្ញុំនិយាយទៅគាត់ថា៖

-សម្តីរបស់បងនេះ ខ្ញុំក៏ធ្លាប់គិត។ តែវារឹតតែធ្វើឲ្យខ្ញុំយល់ថាជីវិតមនុស្សគ្មានន័យសោះ។ សូម្បីតែក្តីសង្ឃឹមចុងក្រោយក៏គ្មានផង... តើមនុស្សគួររស់ធ្វើអ្វីទៅ?

-ប្អូនត្រូវដឹងថា គំនិតត្រឹមត្រូវគឺគំនិតណាដែលផ្តល់នូវប្រយោជន៍។ គំនិតផ្តល់ប្រយោជន៍គឺជាគំនិតនៃក្តីសង្ឃឹម ប៉ុន្តែរាល់ក្តីសង្ឃឹមទាំងអស់ ក៏មិនគួរលុបចោលសេចក្តីពិតដែរ តើមែនទេ?

គិតទៅ ទោះជាមនុស្សពូកែគិតយ៉ាងណាក៏ដោយ បើជួបបញ្ហាហើយ ក៏នៅតែត្រូវការគំនិតរបស់មនុស្សម្នាក់ទៀតដែរ។ ថ្ងៃនេះបើខ្ញុំមិនបាននិយាយជាមួយនឹងបងស្នាដៃទេ ខ្ញុំប្រហែលក្លាយជាឆ្កួតក៏ថាបាន។ គាត់បានផ្តាំខ្ញុំមុនពេលបែកគ្នាថា៖

-កុំនឹកគេខ្លាំងពេក ព្រោះយើងមិនអាចបញ្ជាក់ប្រាប់អ្នកដែលយើងនឹកនោះ ឲ្យយល់ពីទំហំនឹករបស់យើងបានឡើយ។ ឈប់

នឹកគេមិនមែនមានន័យថាឈប់ស្រលាញ់គេទេ គឺគ្រាន់តែឈប់ធ្វើបាបខ្លួនឯងតែប៉ុណ្ណោះ។

ព្រះចន្ទរះកាន់តែខ្ពស់ ធាតុអាកាសកាន់តែត្រជាក់... រដូវរំហើយរុំស្រោបទីក្រុងភ្នំពេញ ឲ្យឮតែសំឡេងខ្យល់បក់ ប្រៀបបាននឹងទីក្រុងមួយស្ថិតនៅឯវាលរហោស្ថាន។ ខណៈនេះខ្ញុំកំពុងជិះរថយន្ត ចេញពីប៉ុស្តិ៍វិទ្យុត្រឡប់ទៅផ្ទះវិញ។ ខ្ញុំតែងធ្វើនូវសកម្មភាពមួយនេះដដែលៗ រហូតទទួលអារម្មណ៍ថា តើជីវិតមនុស្សគួរឲ្យធុញទ្រាន់យ៉ាងនេះឬ?

ពេលចូលទៅដល់ក្នុងផ្ទះ ម៉ាក់នៅអង្គុយមើលទូរទស្សន៍ ក៏ស្រែកហៅខ្ញុំ៖

-លីលី! កូនមកណេះមើល៍!

ខ្ញុំដើរទៅអង្គុយក្បែរគាត់៖

-ម៉ាក់បាត់ផ្កាសាយហើយនៅ?

-ដូចជាបាត់ហើយកូន។ នែកូន... ល្ងាចមិញនេះម៉ាក់មើលព័ត៌មាន ហើយឃើញក្មួយកត្តិក នៅក្នុងពិធីពិព័រណ៌រូបថតមួយ... គេឥឡូវនេះស្គមដល់ហើយ។ តើកូនធ្លាប់បានជួបគេទេ?

-អត់ដែលផងម៉ាក់!

-តាមពិតរឿងកូននិងកត្តិក ទោះជាមិនបានជាគូស្រករ ក៏គួរតែរាប់អានគ្នាដែរ។

ខ្ញុំនៅស្ងៀមបន្តិច ទើបឆ្លើយ៖

-កូនក៏ធ្លាប់គិតអ៊ីចឹងដែរ គ្រាន់តែពួកយើងមិនដែលមានឱកាសបានជួបគ្នាសោះ។ ខ្ញុំចូលក្នុងបន្ទប់សិនហើយម៉ាក់!

ខ្ញុំរៀបនឹងក្រោក ម៉ាក់ក៏ឃាត់៖

-ឈប់សិនកូន! ថ្ងៃមិញម៉ាក់របស់ក្មួយកត្តិក គាត់ទូរស័ព្ទមកលេងម៉ាក់។ ...ម៉ាក់ក៏នាំគាត់និយាយពីកត្តិក ហើយសួរគាត់ថា

តើគាត់មានដណ្ដឹងប្រពន្ធឲ្យគេហើយឬនៅ? គាត់ក៏លើកយករឿងឆ្នាំមុនមកនិយាយ ហើយថាកត្តិក ប្រាប់គាត់ថា គេស្រលាញ់តែកូនឯងម្នាក់ទេ។ ដល់ម៉ាក់សួរគាត់ពីក្មេងស្រីសក់រួញនោះ ថាជាអ្នកណា? ទើបដឹងថា នាងគឺជាកូនស្រីធម៌របស់គាត់...

ស្ដាប់ដល់ត្រឹមនេះ ខ្ញុំហាក់បានភ្ញាក់ពីសុបិន។ ខ្ញុំតែងសុបិនឃើញកត្តិក និងនារីម្នាក់នោះគឺជាគូសង្សារនឹងគ្នា។ ខ្ញុំឱបម៉ាក់ដោយចង់ទាមទារការយល់ចិត្តពីគាត់៖

-ម៉ាក់! កូននឹកគេណាស់។ កូនខានឃើញគេមួយឆ្នាំហើយ។ កន្លងមកកូនតែងប្រាប់ខ្លួនឯងថា កូនស្អប់គេ ទាំងដឹងច្បាស់ថាកូនស្រលាញ់គេជាទីបំផុត...

-នៅលើលោកនេះ គ្មានអ្វីអាចប្រណាំងប្រជែងនឹងពេលវេលាបានទេ។ ឥឡូវនេះពេលវេលាពិតជាអាចធ្វើឲ្យកូនពិសោធចិត្តខ្លួនឯងបានច្បាស់ ហើយក៏អាចបកស្រាយនូវការយល់ច្រឡំ

មួយទៀតផង។ កូនស្រីម៉ាក់! បើកូនស្រលាញ់កត្តិក កូនក៏ត្រូវធ្វើអ្វីដើម្បីក្តីស្រលាញ់របស់កូនដែរ។

ពេលវេលាតែងផ្លាស់ប្តូរធាតុអាកាស ផ្លាស់ប្តូររដូវកាល ផ្លាស់ប្តូរប្រវត្តិសាស្ត្រ ផ្លាស់ប្តូរទាំងចិត្តមនុស្ស ប៉ុន្តែស្នេហាស្មោះប្រហែលជាពេលវេលាផ្លាស់ប្តូរមិនបានឡើយ។ គេថាចង់ឈ្នះស្នេហា គឺត្រូវគេចវេះពីស្នេហា ប៉ុន្តែហេតុអ្វីក៏ត្រូវយកឈ្នះស្នេហា? ទោះបីជាខ្ញុំយកឈ្នះស្នេហាបានមែន តែខ្ញុំនឹងចាញ់ជីវិតខ្លួនឯង។ ឆាកជីវិតខ្លីណាស់ ហេតុអ្វីក៏ខ្ញុំមិនស្វះខ្វល់នឹងចាប់យកសុភមង្គល ដែលរសាត់កាត់មុខខ្ញុំសោះអ៊ីចឹង? ស្រលាញ់មនុស្សម្នាក់ត្រូវផ្តល់ឱកាសឲ្យគេ និងផ្តល់ឱកាសឲ្យខ្លួនឯងផង។ គំនិតអាត្មានិយមរបស់ខ្ញុំ ដែលប្រាថ្នាឲ្យគេស្រលាញ់ខ្លួនខ្លាំងជាងខ្លួនស្រលាញ់គេនោះ បែរជាភ្លេចគិតថាចិត្តខ្លួនឯងស្រលាញ់គេខ្លាំងប៉ុណ្ណាទៅវិញ។

កត្តិក! តើពេលនេះលោកនៅទីណា? ជីវិតពួកយើងដូចជានៅសែនឆ្ងាយពីគ្នាណាស់។ តើយើងលែងមាននិស្ស័យនឹងគ្នាហើយមែនទេ? ខ្ញុំចង់ជួបលោកម្តងទៀត... ចង់សួរលោកថា តើ

លោកស្រលាញ់ខ្ញុំដែរទេ? មានសំណួរជាច្រើនណាស់ដែលខ្ញុំចង់សួរលោក... ប៉ុន្តែពេលនេះមានតែសំណួរមួយនេះទេ ដែលសំខាន់ជាងគេ។

រថយន្តបោលទៅមុខ វាលស្រែទាំងឡាយរត់ថយក្រោយឆ្ងាយទៅៗដាច់កន្ទុយភ្នែក។ ទេសភាពនៅតាមផ្លូវនេះ អាចធ្វើឲ្យមនុស្សគយគន់ដល់ស្រវឹងភ្លេចទុក្ខសោកបាន។ ថ្ងៃនេះខ្ញុំធ្វើដំណើរកាត់ទេសភាពដ៏ត្រកាល ជាមួយមិត្តភក្តិជាច្រើននាក់ដើម្បីទៅកម្សាន្តនៅឯស្រុកស្រែ។ ជីវិតមនុស្សគឺដូចកំពុងតែជិះរថយន្តនេះអ៊ីចឹង គួរណាស់តែចេះត្រេកត្រអាលនឹងទេសភាពនៅតាមផ្លូវ កុំស្ងួវខ្វល់ពីគោលដៅខ្លាំងពេក ព្រោះមុននិងក្រោយគង់តែដល់ដូចគ្នា។ មើលចុះ! វាលស្រែខ្វាត់ខ្វែងរចនាជាក្រឡាឆ្លាស់ពណ៌ ប្រៀបដូចជាកម្រាលព្រំ រួចឃើញដើមត្នោត ដើម

ចារ ដែលឈរដូចអ្នកតាថែរក្សាស្រែស្រូវប្រជាកសិករ លម្អជាមួយរូបទីងមោងឈរឆ្អឹង បង្អើរហ្វូងចាបមិនឲ្យចុះស៊ីស្រូវ។

ទីបំផុតពួកយើងក៏មកដល់គោលដៅ ដោយគ្រាន់តែទុកឲ្យពេលវេលារសាត់ទៅមុខតែប៉ុណ្ណោះ។ ទីស្ថាននោះជាវាលស្រែដែលទើបតែច្រូតហើយថ្មីៗ ផុំក្លិនជញ្ជ្រាំងស្រូវជាប់ច្រមុះ។ រថយន្តមួយទៀតដែលមកដល់ទីនោះមុន ពួកគេនាំគ្នាក្រាលកន្ទេលស្លឹកត្នោត រៀបចំអាហារថ្ងៃត្រង់នៅក្រោមម្លប់ត្នោតបីដើម ដែលកំពុងត្រូវខ្យល់បក់អង្រួនស្លឹក លាន់សូររអឺកដូចគេប្រគំភ្លេង។ មនុស្សទាំងអស់គ្នាមិនបានប្រមូលផ្តុំតែមួយកន្លែងទេ។ អ្នកខ្លះនាំគ្នាទៅលេងបឹងឈូក អ្នកខ្លះទៀតបង្ហោះខ្លែងលេង ហើយក៏មានសង្សារមួយគូ កំពុងអង្គុយសាសងគ្នាក្រោមម្លប់ដើមសង្កែ មើលតែសារិកាញីឈ្មោល។

កម្មវិធីកម្សាន្តនេះ គឺផ្តើមគំនិតដោយប្រិយមិត្តវិទ្យុ ហើយក៏មានពិធីករវិទ្យុមកចូលរួមច្រើនដែរ។ ប្រភា អាចមកចូលរួមដែរទេដឹង? ប៉ុន្មានថ្ងៃមកនេះ ខ្ញុំបានគិតយល់ច្រើនពីស្នេហាខ្ញុំនិងនាង គឺគិតពីនិស្ស័យស្នេហ៍ គិតពីអ្វីហៅថាស្នេហាពិត?

អាចនិយាយថាខ្ញុំនិងប្រភា មាននិស្ស័យនឹងគ្នាមែន ប៉ុន្តែពួកយើងនៅតែគ្មានវាសនា។ ហេតុនេះទើបខ្ញុំយល់ថា មនុស្សដែលមាននិស្ស័យនឹងគ្នាមានអ្វីគួរឲ្យសរសើរទៅ តែអ្វីដែលគួរឲ្យសរសើរ គឺមនុស្សដែលខំកសាងនិស្ស័យដោយខ្លួនឯងទៅវិញទេ។

ចំពោះរឿងស្នេហា បងស្នាដៃនិយាយត្រូវណាស់។ បើយើងស្រលាញ់មនុស្សម្នាក់ពិតប្រាកដ ចាំបាច់ខ្វល់ថា គេស្រលាញ់យើងវិញ ឬក៏អត់ធ្វើអ្វី? ក្តីស្រលាញ់មិនមែនជាតណ្ហា ដែលប្រាថ្នាដើម្បីសុភមង្គលម្នាក់ឯងឡើយ។ ស្នេហាបរិសុទ្ធមិនបាច់គិតពីលទ្ធផលចុងក្រោយ ដោយគ្រាន់តែរក្សាការចងចាំដ៏ល្អមួយសម្រាប់ជីវិត ក៏គ្រប់គ្រាន់។ ស្នេហាប្រាកដជាអាចបង្កើតឡើងតែម្នាក់ឯង រួចក៏បញ្ចប់ទៅវិញតែម្នាក់ឯង ប៉ុន្តែបើយើងមិនចង់បញ្ចប់ ក៏គង់នៅមានស្នេហានោះក្នុងដួងចិត្តយើងរហូត។

ព្រះអាទិត្យខំរះបង្ហួតរស្មីណាស់ដែរ ប៉ុន្តែខ្យល់រដូវនៅតែបក់បោកឲ្យខ្ញុំរងាបាន។ ជំហានខ្ញុំដើរតាមភ្លឺស្រែ សំដៅទៅដើមផ្កាត្របែកព្រៃមួយគុម្ពទាំងមិនដឹងខ្លួន។ ផ្កាត្របែកព្រៃមួយមែក

ដែលនៅចុងខ្ពស់ផុតពីដៃ រីកស្រស់ប៉ប្រិម ហាក់ញញឹមទទួលស្វាគមន៍ខ្ញុំជាភ្ញៀវ។ ខ្ញុំអង្គុយចុះលើភ្លឺស្រែក្បែរដើមត្របែកព្រៃនោះ។ បរិយាកាសជុំវិញខ្លួនសែនមនោរម្យណាស់។ ចាំបានថាខ្ញុំធ្លាប់ស្រមៃចង់មកមើលផ្កាត្របែកព្រៃរីកនៅវាលស្រែ ជាមួយប្រភា តែពេលនេះខ្ញុំបែរជាមកតែម្នាក់ឯង...

-ប្រភា! បងនឹកអូនណាស់!!!

បេះដូងឯកា អារម្មណ៍សែនសង្វេគ បណ្ដាលឲ្យធ្លាយចេញសំឡេងពីដួងចិត្តមកខាងក្រៅ ដើម្បីបានធូរទ្រូង។ ស្រែកពាក្យក្នុងចិត្តនេះរួច ខ្ញុំដកដង្ហើមធំ ភ្នែកសម្លឹងមើលមេឃដ៏ធំល្វឹងល្វើយ ព្រោះចង់អង្វរមេឃឲ្យយល់ចិត្ត...

-កត្តិក! ខ្ញុំក៏នឹកលោកដែរ!!!

...សំឡេងនេះរសាត់មកពីទិសខាងណា? ឱ! ខ្យល់អើយ! ល្ហមឈប់បក់សិនហើយ ទុកឲ្យត្រចៀកខ្ញុំផ្ទៀងស្ដាប់សំឡេងនេះឲ្យច្បាស់។ ហេតុអ្វីក៏ប្រែជាស្ងាត់ឈឹងវិញទៅហើយ? ឬក៏ខ្ញុំស្រមៃទេដឹង? ទោះយ៉ាងណាបេះដូងខ្ញុំនៅតែលោតញាប់

ដង្ហើមខ្ញុំនៅតែដកដង្ហក់ ព្រោះត្រចៀកខ្ញុំស្តាប់ឮច្បាស់ណាស់ថាសំឡេងនេះកំពុងតែនៅជិតខ្ញុំបង្អើយ...

-សួស្តីលោក!

គ្រានោះសំឡេងខ្យល់ក្លាយជាស្ងាត់ជ្រងំ ទុកឲ្យសំឡេងបេះដូងសាសងគ្នា... ហើយពេលវេលាក៏ត្រូវឃាត់ឲ្យឈប់ដើរទៅមុខត្រឹមហ្នឹង...

នេះហើយគឺជាស្នេហារបស់យើងទាំងពីរនាក់...
ស្នេហាឆ្លាក់ចារដោយធាតុអាកាសដ៏សែនត្រជាក់
តាក់តែងដោយខ្យល់ដែលបក់ត្រសៀកៗពីទិសឧត្តរ
ហើយកើតឡើងនៅក្រោមពន្លឺព្រះអាទិត្យភ្លឺត្រចះ
និងក្រោមវស្សារាត្រីដ៏ត្រជាក់ស្រឹប...
គឺជាស្នេហាដំស្ដុំដោយនិស្ស័យខ្យល់ខែរងា...
ទេសភាពខែរងាមិនរុះរោយពីដួងចិត្តមនុស្សឡើយ
ហើយមនុស្សក្រវីរីយ៍ខែរងា
នៅតែត្រសូបផ្គួលពេញពោះដួងពួកយើងជានិរន្តរ៍។

គ្រប់មាតិកានៃរឿងនេះជាកម្មសិទ្ធិបញ្ញា
របស់អ្នកនិពន្ធ សុខ ចាន់ផល

នេះគឺជាសៀវភៅរឿងប្រលោមលោកបែបច្នៃប្រឌិត។ ឈ្មោះតួអង្គ ទីកន្លែង និង
ហេតុការណ៍តួអង្គនៅក្នុងសៀវភៅនេះ សុទ្ធតែជាការស្រមើស្រមៃ។
រាល់ព្រឹត្តិការណ៍ ដែលស្រដៀង ឬដូចគ្នាទៅនឹងភាពជាក់ស្តែង បុគ្គល (នៅរស់ ឬស្លាប់)
និងទីកន្លែង ឬស្ថាប័ន គឺជាការចៃដន្យតែប៉ុណ្ណោះ។

គណៈកម្មការអំណាន៖
ឈុន ឃុនវិរិយ៉ា, លឹម គីមឈុន, ហេង ឧត្តម, សាត បញ្ញា

រចនាក្រប៖
ខាំ ភូរិ, ហួត លី, កៅ សីហា, ធី សុផាន់ណា

បោះពុម្ពជាសៀវភៅលើកទីមួយ ចំនួន ១០០០ ក្បាល
នៅប្រទេសកម្ពុជា ឆ្នាំ 2010
ISBN-978-99950-968-3-0

ឧបត្ថម្ភដោយ
សហគមន៍ខ្មែរ នៅទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា
តាមរយៈអ្នកស្រី លឹម សន្តិភាព

អនុស្សាវរីយ៍

Phone: 0888817999
Email: chanphalsok@yahoo.com
Blog: www.sokchanphal.info



ប្រលោមលោកនេះ ខ្ញុំសរសេរកាលពីខែរងាឆ្នាំ២០០៦
គឺបរិយាកាសខែរងានោះបានផ្ដល់សាច់រឿងនេះឱ្យខ្ញុំ...
ឆ្នាំ២០០៦ ស្រុកខ្មែរចូលខែរងានៅពាក់កណ្ដាលខែធ្នូ មានរយៈពេលខ្លីទេ
តែល្មមនឹងខ្ញុំអាចសរសេរប្រលោមលោកមួយនេះចប់។
សាច់រឿងពីដើមដល់ចប់ ក៏កើតឡើងក្នុងខែរងា
គឺ ឆ្នាំ២០០៦ ឆ្នាំ២០០៧ និង ឆ្នាំ២០០៨ ។
ខ្ញុំបានសរសេរឱ្យតួអង្គពីរនាក់ ប្រាប់រឿងរបស់ពួកគេម្ដងម្នាក់ដល់អ្នកអាន
ហើយខ្ញុំគិតថាវាជារចនាបថប្លែកមួយទៀត នៃសៀវភៅប្រលោមលោកខ្មែរ។

ខ្ញុំមានពាក្យអរគុណជាច្រើនចង់និយាយ... អរគុណមិត្តទាំងអស់គ្នា
តែងតែផ្ដល់កម្លាំងចិត្ត និងគាំទ្រស្នាដៃនានារបស់ខ្ញុំ
មិនថាតែប្រលោមលោក ឬក៏បទចម្រៀង... អរគុណមិត្តនៅ
Blog: sokchanphal.wordpress.com និង facebook
អរគុណចំពោះវត្តមានរបស់អ្នកក្នុងជីវិតរបស់ខ្ញុំ។

យុវអ្នកនិពន្ធខ្មែរ
KHMER YOUTH WRITER

អនុស្សាវរីយ៍
www.sokchanphal.info

9 789995 096830